Australian Government

NATIONAL BOWELCANCER
SCREENING PROGRAM

## ឈ្មោះផលិតផល

គ្រឿងប្រដាប់សម្រាប់កម្មវិធីជាតិលើការពិនិត្យរកមើលជម្ងឺមហារីកពោះវៀន

## កិច្ចបំរីផ្នែករោគសាស្ត្រ

Dorevitch PATHOLOGY

ផ្ញើ "ស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ" ដែលមានដាក់សំណាកលាមកសម្រាប់ធ្វើតេស្តរបស់លោកអ្នកទៅ:

Reply Paid 83974
Dorevitch Pathology
FOBT Department
PO Box 5018
Heidelberg West MDC VIC 3081

## អ្នកធានាឧបត្ថម្ភនៃ

NEW HEMTUBE (B)

SIEMENS

## រោងចក្រផលិតនៃ

NEW HEMTUBE (B)

FUJIREBIO INC.

FOBT002 Version 12/12

## ការរក្សាទុកសំណាកលាមករបស់អ្នក

- រក្សាទុកស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ ដែលមានដាក់សំណាកលាមករបស់លោកអ្នកនៅកន្លែងត្រជាក់ក្នុងសីតុណ្ហភាពរវាង ២អង្សា និង១០អង្សា ទូទឹកកកគឺជាកន្លែងល្អសមរម្យជាងគេបំផុត សម្រាប់រក្សាទុកសំណាកលាមករបស់លោកអ្នក។

កុំ:

- ផ្លាស់ប្តូររបបអាហារបរិភោគ ឬថ្នាំព្យាបាលរបស់លោកអ្នកឲ្យសោះ។
- ដាក់សំណាកលាមករបស់លោកអ្នកនៅកន្លែងត្រជាក់កកឲ្យសោះ។

កុំប្រមូលសំណាកលាមក ប្រសិនបើ:

- លោកអ្នកមានរោគឫសដូងបាតដែលហូរចេញឈាម។
- វាស្ថិតនៅក្នុងអំឡុងពេលមានរដូវ ឬពេល៣ថ្ងៃមុន ឬពេល៣ថ្ងៃក្រោយអំឡុងពេលមានរដូវ។
- ឃើញមានឈាមនៅក្នុងទឹកនោមរបស់លោកអ្នក ឬឃើញមានឈាមនៅក្នុងលាមក - នៅក្នុងករណីនេះ លោកអ្នកគួរទាក់ទងវេជ្ជបណ្ឌិតរបស់លោកអ្នក។
- លោកអ្នកបានរៀបចំពេលឲ្យទៅថតវិភាគពិនិត្យមើលពោះវៀនធំនៅពេលឆាប់ៗខាងមុខនេះ។
- លោកអ្នកធ្លាប់មានរោគពោះវៀនធំក្នុងរយៈពេល១២ខែកន្លងទៅ ហើយកំពុងទទួលការព្យាបាលក្នុងពេលបច្ចុប្បន្ន - សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកមិនច្បាស់ប្រាកដទេ។

NATIONAL BOWELCANCER
SCREENING PROGRAM

Australian Government

# របៀបប្រមូល សំណាកលាមករបស់លោកអ្នក សម្រាប់ការធ្វើតេស្ត>>>

## តើត្រូវការជំនួយឬទេ?

សូមទូរស័ព្ទលេខ 1800 738 365
ពីថ្ងៃច័ន្ទ - ថ្ងៃសុក្រ (ពេលម៉ោងក្នុងតំបន់ខាងកើតប្រទេសអូស្ត្រាលី - AEST)
ចាប់ពីម៉ោង៩ព្រឹក ដល់ម៉ោង៥រសៀល

**តើមានការលំបាកក្នុងការអានភាសាអង់គ្លេសឬ?**

សូមទូរស័ព្ទមកយើងលេខ 13 14 50

សូមអានឲ្យបានគ្រប់ទំព័រទាំងអស់ មុននឹងអនុវត្តវិធានការដ៏ងាយស្រួលទាំង៩ ដើម្បីប្រមូលយកសំណាកលាមកទាំំងពីរលើករបស់លោកអ្នក។

ធ្វើបានឆាប់ ងាយស្រួល ក្នុងផ្ទះរបស់លោកអ្នក នៅពេលសមរម្យសម្រាប់លោកអ្នក។

# ការប្រមូលសំណាកលាមក លើកទីមួយរបស់លោកអ្នក 1

- ប្រើ**បន្ទះពណ៌ខៀវ**។
- បត់ជើងតូចឲ្យចេញអស់ពីផ្លោកនោមរបស់លោកអ្នក រួចមកចាក់បង្ហូរទឹកបង្គន់។
- ដាក់បណ្ដោតសន្លឹកក្រដាសប្រមូលសំណាកលាមក ដោយដាក់ផ្នែកបោះពុម្ពនៅខាងលើ ពីលើផ្ទៃទឹកក្នុងជើងបង្គន់។
- អង្គុយលើបង្គន់ ហើយបញ្ចេញលាមកទៅលើសន្លឹកក្រដាសប្រមូលសំណាកលាមក។
- សន្លឹកក្រដាសប្រមូលសំណាកលាមកនឹងមិនប៉ះពាល់ដល់ប្រព័ន្ធបង្គន់ឡើយ នៅពេលចាក់បង្ហូរទឹក។
- ដាក់ចុង**បន្ទះពណ៌ខៀវ**ទៅក្នុងលាមករបស់លោកអ្នក រួចមកទាញអូសវា (កកិត)ទៅមុខ និងទៅក្រោយ រហូតទាល់តែលោកអ្នកមានលាមកដែលប៉ះជាប់នៅខាងចុងបន្ទះ មានទំហំមិនធំជាងគ្រាប់អង្ករឡើយ។




- រុញ**បន្ទះពណ៌ខៀវ**ទាំងស្រុងទៅក្នុងបំពង់សម្រាប់ប្រមូលសំណាកលាមករហូតទាល់តែវាបិទឮសូរគ្លិក។

  *សូមកុំព្រួយបារម្ភ ប្រសិនបើទំនងជាមើលឃើញថាសឹងតែគ្មានលាមកណាបន្តិចសោះ ដែលបានដាក់ចូលទៅក្នុងវត្ថុរាវក្នុងបំពង់សម្រាប់ប្រមូលសំណាកលាមក។*



- សំខាន់ > កុំដក**បន្ទះពណ៌ខៀវ**សម្រាប់ប្រមូលសំណាកលាមក ចេញពីបំពង់ឲ្យសោះ ក្រោយពីបានស៊កវាចូលហើយ។

# ការបិទស្លាកព័ត៌មាន និងរក្សាទុកសំណាក លាមករបស់លោកអ្នក 2

- សរសេរ "ឈ្មោះ" របស់លោកអ្នកជាអក្សរធំ "ថ្ងៃខែឆ្នាំកំណើត" និង "ថ្ងៃខែផ្ញើសំណាកលាមក" លើស្លាកព័ត៌មាន ហើយបិទវាជុំវិញបំពង់ប្រមូលសំណាកលាមក។
- ដាក់បំពង់ប្រមូលសំណាកលាមក ទៅក្នុងបំពង់ធំមានគម្របមួលបិទសម្រាប់ដឹកជញ្ជូន។




បិទស្លាកព័ត៌មានលើបំពង់សម្រាប់ប្រមូលសំណាកលាមក **ពុំមែន**បិទលើបំពង់សម្រាប់ដឹកជញ្ជូនឡើយ




- មួលគម្របបិទ ហើយដាក់ចូលទៅក្នុងថង់ប្លាស្ទិកមានខ្សែរូតសម្រាប់ទាញបិទ។ បិទឲ្យជិត។
- ដាក់ថង់ប្លាស្ទិកមានខ្សែរូតបិទជិត ទៅក្នុងស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ។
- សំខាន់ > រក្សាទុកស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ ធ្វើយ៉ាងណាឲ្យសំណាកលាមករបស់លោកអ្នកនៅក្នុងសីតុណ្ហភាពរវាង២អង្សា និង១០អង្សា - ទូទឹកកក គឺជាកន្លែងមួយដ៏ល្អ។
- សំខាន់ > កុំទុកវាក្នុងកន្លែងធ្វើឲ្យកកឡើយ។

# ការប្រមូលសំណាកលាមក លើកទីពីររបស់លោកអ្នក 3

- ប្រើ**បន្ទះពណ៌ក្រហម**។
- យកល្អ សំណាកទីពីរគួរតែប្រមូលក្នុងរង្វង់ពេល ២-៣ថ្ងៃ។ លោកអ្នកអាចយកសំណាកលាមកទី២ នៅពេលក្រោយក្នុងថ្ងៃដដែល ប្រសិនបើលោកអ្នកចង់ធ្វើយ៉ាងនេះ។
- ធ្វើតាមជំហានទាំងអស់ឡើងវិញ ដូចគ្នានឹង "១. ការប្រមូលសំណាកលាមកទីមួយរបស់លោកអ្នក" និង "២. ការសរសេរស្លាកព័ត៌មាន និងរក្សាទុកសំណាកលាមករបស់លោកអ្នក"។
- ដាក់បំពង់សម្រាប់ដឹកជញ្ជូនទៅក្នុងថង់ប្លាស្ទិកមានខ្សែរូតទាញបិទ ជាមួយបំពង់ដទៃទៀត បន្ទាប់មកដាក់ក្នុងស្រោមសំបុត្រសម្រាប់ផ្ញើ។





- សំខាន់ > សូមបន្តរក្សាទុកស្រោមសំបុត្រនេះក្នុងកន្លែងដែលមានសីតុណ្ហភាពរវាង២អង្សា និង១០អង្សា រហូតទាល់តែលោកអ្នកបានផ្ញើវាតាមប្រៃសណីយ៍។
- សំខាន់ > សូមកុំទុកវាក្នុងកន្លែងធ្វើឲ្យកកឡើយ។

# បញ្ជីផែកមើលសម្រាប់ ការផ្ញើតាមប្រៃសណីយ៍ 4

- នៅលើផ្នែកខាងមុខនៃស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ សូមចុះហត្ថលេខារបស់លោកអ្នកក្នុងកន្លែង "ហត្ថលេខាអ្នកផ្ញើ"។
- នៅលើខ្នងស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ សូមបំពេញ "ឈ្មោះអ្នកផ្ញើ" និង "អាសយដ្ឋានអ្នកផ្ញើ"។ **ដាក់ទៅក្នុងស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវដែលបានបង់ថ្លៃតែម្ដងរួចស្រេច:**
- សំខាន់ > ចុះហត្ថលេខា និងចុះថ្ងៃខែក្នុងហ្វ៊មព័ត៌មានលំអិតរបស់អ្នកចូលរួម ដែលដាក់នៅក្នុងស្រោមសំបុត្រធំដែលមានប្រអប់ NBCSP របស់លោកអ្នក។
- ថង់ប្លាស្ទិកដែលមានខ្សែរូតទាញបិទមានបំពង់សម្រាប់ប្រមូលសំណាកលាមកពីរមានបិតស្លាកព័ត៌មាន ដែលបានដាក់ទៅក្នុងបំពង់មានគំរបមួលបិទសម្រាប់ដឹកជញ្ជូន។
- ផ្ញើវត្ថុសម្រាប់ធ្វើតេស្តរបស់លោកអ្នកដែលបានបំពេញរួច ឲ្យបានឆាប់បំផុត តាមដែលលោកអ្នកអាចធ្វើបាន។
- នៅពេលធ្វើដំណើរទៅផ្ញើស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវ សូមរក្សាវាឲ្យនៅស្ងួត និងត្រជាក់ (ក្រោម២៥អង្សា)។

  ផ្ញើស្រោមសំបុត្រសម្រាប់ផ្ញើពណ៌ខៀវនៅតាមហាង/ការិយាល័យ Australia Post ។

  ប្រសិនបើការនេះពុំអាចធ្វើបានទេ សូមផ្ញើតាមប្រអប់សំបុត្ររបស់ Australia Post ។

**តើត្រូវការជំនួយឬទេ? ព័ត៌មាន** • ទូរស័ព្ទ 1800 738 365។ ថ្ងៃច័ន្ទ - ថ្ងៃសុក្រ (ពេលម៉ោងក្នុងតំបន់ខាងកើតប្រទេសអូស្ត្រាលី - AEST) រវាងម៉ោង៩ព្រឹក ទៅម៉ោង៥រសៀល • **លំបាកក្នុងការអានភាសាអង់គ្លេស** • **កិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ** • ទូរស័ព្ទ 13 14 50 • **វិបសាយ** www.cancerscreening.gov.au